# **របាយការណ៍ប្រចាំខែកញ្ញា ឆ្នាំ ២០១៤ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ**

នៅក្នុងខែកញ្ញា ឆ្នាំ២០១៤ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **ស្ថានភាពមន្ត្រីរាជការ**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣១ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប។

2. **សកម្មភាពថ្នាក់ដឹកនាំមន្ទីរ**÷

- ចូលរួមផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការប្រើប្រាស់ធនធានមនុស្ស និងផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ ថ្ងៃទី២៧/០៨/២០១៤ នៅសាលមហោស្រពខេត្តក្រចេះ
- ចូលរួមប្រជុំការបើកទូលាយដើម្បីត្រួតពិនិត្យវាយតម្លៃ សកម្មភាពការងារគ្រប់ផ្នែករយៈពេល ០១ ឆ្នាំ របស់រដ្ឋបាលសាលាខេត្តក្រចេះ ថ្ងៃទី២៩/០៨/២០១៤
- ចូលរួមសម្ពោធអគារសិក្សា ០១ ខ្នង ០៣ បន្ទប់ ជាអំណោយរបស់ក្រុមហ៊ុន HRI ប្រជាពលរដ្ឋជប៉ុន នៅភូមិល្អត់ ឃុំថ្មអណ្តើក ស្រុកចិត្របុរី ថ្ងៃទី០៣/០៩/២០១៤
- ចូលរួមចែកប័ណ្ណកម្មសិទ្ធដីធ្លីជូនប្រជាពលរដ្ឋ ឃុំស្នួល ស្រុកស្នួល នៅសាលមហោស្រពខេត្តក្រចេះ ថ្ងៃទី០៣/០៩/២០១៤ ក្រោមអធិបតីភាព **ឯកឧត្តម ទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម**
- ចូលរួមរៀបចំឯកសារក្រោយប្រជុំតំបន់អភិវឌ្ឍន៍ត្រីកោណ (CLV) ថ្ងៃទី០៣/០៩/២០១៤ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមវេទិការសាធារណៈជួបប្រជាពលរដ្ឋនៅឃុំហាន់ជ័យស្រុកឆ្លូងថ្ងៃទី០៧/០៩/២០១៤
- ចូលរួមប្រកាសផ្ទេរភារកិច្ច តែងតាំងមុខតំណែងស្នងការនៃស្នងការនគបាលខេត្តក្រចេះ ថ្ងៃទី០៨/០៩/២០១៤ នៅសាលមហោស្រពខេត្តក្រចេះ
- ចូលរួមកាន់បិណ្ឌនៅវត្តប៉ាឆា និងវត្តកសាង ជាមួយ **ឯកឧត្តមអភិបាលខេត្តក្រចេះ** ថ្ងៃទី០៨ និងថ្ងៃទី ១៤/០៩/២០១៤
- ចូលរួមប្រជុំសាមញ្ញលើកទី៤ អាណត្តិទី២ ឆ្នាំទី១ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី១១/០៩/២០១៤ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមប្រជុំណែនាំស្តីពីការរៀបចំតារាងវិភាគស្ថានភាពខេត្ត ក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ ៥ ឆ្នាំរបស់ខេត្ត ថ្ងៃទី១៧/០៩/២០១៤ នៅសាលប្រជុំខេត្តក្រចេះ
- ចូលរួមប្រជុំពិភាក្សាអំពីការសុំអនុញ្ញាតបណ្តាញទឹកទំនើបកម្ម ប្រើដោយថាមពលព្រះអាទិត្យ ថ្ងៃទី២៥/០៩/២០១៤ នៅសាលប្រជុំខេត្តក្រចេះ ។

3. **សកម្មភាពតាមការិយាល័យ**÷

3.1. **ការិយាល័យរដ្ឋបាល និងបុគ្គលិក**÷

ក. ផ្នែកការងារលិខិតចូល÷ សរុបចំនួន ៧០ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០២ លេខ
- លិខិតរបស់ក្រសួងសាមី ចំនួន ០៨ លេខ
- លិខិតក្រសួងនានា ចំនួន ១៦ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៤៤ លេខ

ខ. ផ្នែកការងារលិខិតចេញ÷ សរុបចំនួន ២៨ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួងសាមី ចំនួន ០៣ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ២៥ លេខ

គ. ផ្នែកការងារលិខិតបញ្ជាបេសកកម្ម÷ សរុបចំនួន ២១ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកម្មលោកប្រធានមន្ទីរ ពី **ឯកឧត្តម អភិបាលខេត្ត** ចំនួន០២ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រី ចំនួន ១៩ លេខ

ឃ. ផ្នែកបញ្ជីវត្ថុមាន÷ ពិនិត្យការចុះបញ្ជីវត្ថុមានជាប្រចាំថ្ងៃ ។

## 3.2. ការិយាល័យផ្លូវលំជនបទ÷

### 3.2.1 លទ្ធផលការងារ÷

- ការងារជួសជុលផ្លូវបន្ទាន់ ភូមិកសាង ឃុំចង្រ្កង់ ស្រុកចិត្របុរី ប្រវែង ២.៤០០ ម៉ែត្រ សម្រេចលទ្ធបាន ១០០%។
- ការងារថែទាំផ្លូវជាលក្ខណៈប្រចាំ ផ្លូវបន្ទាយទៅបុស្សផល ឃុំគោលាប់ ប្រវែង ១០.៤០០ ម៉ែត្រ និងផ្លូវចង្រ្កង់ទៅថ្មគ្រែ ឃុំចង្រ្កង់ ក្នុងស្រុកចិត្របុរី ប្រវែង ៨.០០០ ម៉ែត្រ សម្រេចលទ្ធផល ៨០%។
- ការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ភូមិអូរព្រះទៅភូមិខ្សាច់លាវ ឃុំអូរគ្រៀង ស្រុកសំបូរ ប្រវែង ១០.០០០ ម៉ែត្រ សម្រេចលទ្ធផលបាន ៦០%។

### 3.2.2 សកម្មភាពការិយាល័យ÷

- ចុះពិនិត្យការសាងសង់ស្ពានបេតុង ១កន្លែង ភូមិជើងពាត ឃុំកោះខ្ញែរ ស្រុកសំបូរ ។
- លោកប្រធានមន្ទីរ អនុប្រធានមន្ទីរទទួលបន្ទុក និងមន្ត្រីការិយាល័យផ្លូវលំជនបទ ចំនួន ៣នាក់ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធី Are GIS10 និងការប្រើប្រាស់ GPS នៅខេត្តរតនគីរី ។

## 3.3. ការិយាល័យផ្គត់ផ្គង់ទឹកជនបទ÷

- ចុះចែកសម្ភារគ្រោះទឹកជំនន់ដល់ប្រជាពលរដ្ឋនៅតំបន់គោលដៅ ទាំង៣ស្រុក ៥ ឃុំស្មើ ២៥ ភូមិ មានធុងចំរោះ ចំនួន ១៥០ ធុង,សាប៊ូ LUXចំនួន ៣៣៦៨ដុំ,កានដាក់ទឹកចំណុះ ២០ លីត្រចំនួន ១៥២០ កាន, ធុងទឹកចំណុះ២០លីត្រ ចំនួន ១.០០០ ធុង, សាប៊ូដុំចំនួន ១.៥២០

ដុំ, ថ្នាំ Acpuatabs (អាក្វាថេប) ចំនួន ១០៤.០០០ បន្ទះ, ថ្នាំ Water Maker (ភ័រ )ចំនួន ៤៨.០០០ កញ្ចប់និងខិតប័ណ្ណរូបភាពចំនួន ៦.០៨០ សន្លឹកក្នុងនោះ÷

- ឃុំកោះតាស៊ុយស្រុកព្រែកប្រសព្វ ធុងចំរោះចំនួន៨០ធុង, កានដាក់ទឹកចំណុះ២០លីត្រ ចំនួន ៥៥០ កាន,សាប៊ូដុំចំនួន ៣០០ដុំ ថ្នាំ Acpuatabs (អាក្វាថេប) ចំនួន ២៥.៨០០ បន្ទះ,ថ្នាំ Water Maker (ភ័រ)ចំនួន ៨.៥០០ កញ្ចប់និងខិតប័ណ្ណ រូបភាពចំនួន ១.២៨០ សន្លឹក
- ឃុំពង្រ ស្រុកឆ្លូង កានដាក់ទឹកចំណុះ២០លីត្រចំនួន ៦២០ កាន,សាប៊ូដុំចំនួន ៣០០ដុំ ថ្នាំ Acpuatabs (អាក្វាថេប) ចំនួន ២៥.០០០ បន្ទះ,ថ្នាំ Water Maker (ភ័រ) ចំនួន ១២.៧០០ កញ្ចប់ និងខិតប័ណ្ណរូបភាពចំនួន ១.២០០ សន្លឹក
- ឃុំបុសលាវ,ឃុំដារ,ឃុំកោះច្រែង ស្រុកចិត្របុរី ធុងចំរោះចំនួន ៧០ ធុង,សាប៊ូក្រអូប (LUX)ចំនួន៣.៣៦៨ដុំ,កានដាក់ទឹកចំណុះ២០លីត្រចំនួន ៣៥០ កាន,ធុងទឹកចំណុះ ២០លីត្រចំនួន ១.២០០ ធុង,សាប៊ូដុំចំនួន ៣៧០ ដុំ,ថ្នាំ cpuatabs (អាក្វាថេប) ៣៥.២០០ បន្ទះ, ថ្នាំWaterMaker(ភ័រ) ចំនួន ២៦.៨០០ កញ្ចប់ និងខិតប័ណ្ណរូបភាព ចំនួន ៣.៦០០ សន្លឹក ។

- ចុះជួសជុលអណ្តូងស្នប់បានចំនួន ១១ អណ្តូង នៅក្នុងក្រុងក្រចេះ មានភូមិកាប៉ូ ០៨ អណ្តូង និង ភូមិស្រែស្តៅ ០៣ អណ្តូង ក្នុងសង្កាត់អូរឬស្សី,ស្រុកចិត្របុរីបានចំនួន ៣៤ អណ្តូង មានឃុំកន្ទួត ០១ អណ្តូង ឃុំគោលាប់ ១៦ អណ្តូង ឃុំបុសលាវ ០២ អណ្តូង ឃុំដា ១៥ អណ្តូង ។

3.4. **<u>ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ÷</u>** (គ្មានសកម្មភាព)

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍÷</u>**

- បានសម្របសម្រួលបង្កើត គ.អ.ភ នៅភូមិសំបូរសែនជ័យ ឃុំស្វាយជ្រះ ស្រុកស្នួល
- ចុះតាមដានសមាសភាព គ.អ.ភ ចំនួន ៨ ភូមិ នៅឃុំស្វាយជ្រះ ស្រុកស្នួល
- ចុះជួបឃុំស្វាយជ្រះដើម្បីសម្របសម្រួល ក្នុងការចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាព គ.អ.ភ សំបូរសែនជ័យ ឃុំស្វាយជ្រះ ស្រុកស្នួល
- ជួបប្រជុំ និងរៀបចំផែនការបណ្តុះបណ្តាល គ.អ.ភ ជាមួយអង្គការ (Child Fund)
- រៀបចំផែនការឆមាសទី០២ សម្រាប់ឆ្នាំ២០១៤ ដើម្បីត្រួតពិនិត្យ តាមដាន និងសម្រួលបញ្ជីឈ្មោះ គ.អ.ភ នៅស្រុកស្នួល
- រៀបចំឯកសារ និងរបៀបវារៈ សម្រាប់បណ្តុះបណ្តាល គ.អ.ភ សំបូរសែនជ័យ ឃុំស្វាយជ្រះ ។

3.6. **<u>ការិយាល័យជនជាតិដើមភាគតិច÷</u>** (គ្មានសកម្មភាព)

3.7. **<u>ការិយាល័យថែទាំសុខភាពជនបទ÷</u>**

- ចុះប្រជុំជ្រើសរើសអ្នកសាងសង់បង្គន់អនាម័យដោយស្ម័គ្រចិត្តបាន ១៥០គ្រួសារ ក្នុងនោះ÷

- ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វបាន ៣០គ្រួសារ
- ឃុំវឌ្ឍនៈស្រុកសំបូរ បាន ១២០ គ្រួសារ ។

3.8. **ការងារបណ្តុះបណ្តាលមន្ត្រីរាជការ÷**

- លោក លឹម ជាវហាវ ប្រធានមន្ទីរ និង លោក សុខ ស៊ីថា ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីលិខិតបទដ្ឋានគតិយុត្ត និងការគ្រប់គ្រងធនធានមនុស្ស និងការផ្តល់សេវាកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ នៅខេត្តក្រចេះ ឧបត្ថម្ភដោយសាលាខេត្ត ។
- លោក លឹម ជាវហាវ លោក ធន សារី លោក ឱក រ៉េត លោក តុញ យ៉ាវ និងលោក សេង ឡុងឌី បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធី Arc GIS 10 និងពង្រឹងការប្រើប្រាស់ GPS ចាប់ពីថ្ងៃទី០៣-០៥ ខែកញ្ញា ឆ្នាំ២០១៤ នៅខេត្តរតនគីរី ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ។
- លោក មាន គឹមតេង អនុប្រធានការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការចងក្រងផែនការគ្រប់គ្រងព្រៃឈើ កាលពីថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០១៤ នៅខេត្តក្រចេះ ឧបត្ថម្ភដោយរដ្ឋបាលព្រៃឈើ ។
- លោក លឹម ជាវហាវ និងលោក សន ធី ប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ បានចូលរួមសិក្ខាសាលាពីការបញ្ចូលផែនការថវិកា ឆ្នាំ ២០១៥ រវាងថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាសម្រាប់រាជធានីខេត្ត កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ នៅខេត្តព្រះសីហនុ ឧបត្ថម្ភដោយក្រសួងអភិវឌ្ឍន៍ជនបទ ។
- លោក ឈាង ស៊ីថា អនុប្រធាបការិយាល័យបណ្តុះបណ្តាល និងលោក អ៊ុត អុល ប្រធានការិយាល័យផែនការ និងស្ថិតិ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ក្រុង ស្រុក ខ័ណ្ឌ ចាប់ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១៤ នៅស្រុកស្នួល និងស្រុកព្រែកប្រសព្វ ឧបត្ថម្ភដោយសាលាស្រុកស្នួល និងសាលាស្រុកព្រែកប្រសព្វ ។

4. **ទិសដៅបន្ត÷**

- បន្តការងារជួសជុលផ្លូវថែទាំជាលក្ខណៈខួប ផ្លូវភូមិអូរព្រះទៅភូមិខ្សាច់លាវ ប្រវែង ១០.០០០ ម៉ែត្រ ឃុំអូរគ្រៀង ស្រុកសំបូរ
- បន្តធ្វើការងារថែទាំផ្លូវជាលក្ខណៈប្រចាំ ផ្លូវបន្ទាយទៅបុស្សផល ឃុំគោលាប់ ប្រវែង ១០.៤០០ ម៉ែត្រ និងផ្លូវចង្រ្កង់ទៅថ្មគ្រែ ឃុំចង្រ្កង់ ប្រវែង ៨.០០០ ម៉ែត្រ ក្នុងស្រុកចិត្របុរី
- បន្តជួសជុលផ្លូវភូមិឈ្វេទៅភូមិស្រែទ្រៀក ឃុំដំរីផុង ស្រុកឆ្លូង ប្រវែង ១៩.២០០ ម៉ែត្រ
- បន្តជួសជុលអណ្តូងស្នប់ ស្រុកសំបូរ

- បន្តការងារចុះត្រួតពិនិត្យ តាមដាន និងសម្រួលបញ្ជីឈ្មោះគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅតាមភូមិនានា នៅស្រុកស្ទួល ខេត្តក្រចេះ
- ផ្សព្វផ្សាយ និងតាមដានការសាងសង់បង្គន់ចាក់ទឹក នៅឃុំព្រែកសាម៉ាន់ ឃុំកញ្ជរ ស្រុកឆ្លូង, ឃុំសណ្ដាន់ ឃុំសំបូរ ស្រុកសំបូរ, ឃុំថ្មគ្រែ ឃុំគោលាប់ ឃុំបុសលាវ ឃុំសំបុក ស្រុកចិត្របុរី និងឃុំសោប ឃុំព្រែកប្រសព្វ ឃុំចំបក់ ឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ។

**ប្រធានមន្ទីរ**